# ធម៌នមស្ការ និង បរិត្តបាលិ

ប្រមូលចងក្រងដោយ ហួយ វ៉ាន់ថន

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ពុទ្ធសករាជ ២៥៦០

| | |
|---|---|
| ឈ្មោះសៀវភៅ | នមស្ការ និងបរិត្តបាលិ |
| ប្រមូលចងក្រងដោយ | ហួយ វ៉ាន់ថន |
| ការផ្សាយ | ពុទ្ធិកបណ្ឌិតសភានៃសាកល<br>វិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| សម្រាប់ជា | ធម្មទាន |
| ព.ស. | ២៥៦០ |

## អានិសង្សនៃការចម្រើនពុទ្ធានុស្សតិ

*នៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា បិដកលេខ ៥២ ទំព័រ ៤៥ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា*

យំ កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ
សំវច្ឆរំ យជេថ បុញ្ញាបេក្ខោ
សព្វម្បិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជ្ជុគតេសុ សេយ្យោ ។

*បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់ចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយប្រសើរជាង ។*

*ខាងក្រោមនេះ ជាអានិសង្សនៃការចម្រើនពុទ្ធានុស្សតិ ដែលមានសម្តែងក្នុងគម្ពីរវិសុទ្ធិមគ្គ*

១. សត្ថរិ សគារវោ ហោតិ សប្បតិស្សោ *ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែងចំពោះព្រះសាស្តា ។*

២. សទ្ធាវេបុល្លំ សតិវេបុល្លំ បញ្ញាវេបុល្លំ បុញ្ញវេបុល្លញ្ច អធិគច្ឆតិ *រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ដោយសទ្ធាផង នូវការពេញបរិបូណ៌ដោយសតិផង នូវការពេញបរិបូណ៌ដោយបញ្ញាផង នូវការពេញបរិបូណ៌ដោយបុណ្យកុសល ។*

៣. បីតិបាមោជ្ជពហុលោ ហោតិ *ជាអ្នកចម្រើនទៅដោយបីតិនិងបាមោជ្ជៈ ។*

៤. ភយភេរវសហោ ទុក្ខាធិវាសនសមត្ថោ *អត់ធន់ចំពោះភ័យ និងហេតុដែលគួរខ្លាច ជាអ្នកអាចអត់សង្កត់សេចក្តីទុក្ខ ។*

៥. សត្ថារា សំវាសសញ្ញំ បដិលភតិ *រមែងបានចំពោះនូវសេចក្តីសម្គាល់ថា ដូចជាបាននៅរួមជាមួយព្រះសាស្តា ។*

៦. ពុទ្ធគុណានុស្សតិយា អជ្ឈាវុត្ថញ្ចស្ស សរីរម្បិ ចេតិយ-ឃរមិវ បូជារហំ ហោតិ *សូម្បីសរីរៈរបស់បុគ្គលនោះ កាលរលឹករឿយៗ នូវគុណព្រះពុទ្ធគ្រប់គ្រងហើយ ជាកាយគួរដល់ការបូជា ដូចជាផ្ទះនៃចេតិយ ។*

៧. ពុទ្ធភូមិយំ ចិត្តំ នមតិ *ចិត្តរមែងបង្អោនទៅក្នុងពុទ្ធភូមិ ។*

៨. វីតិក្កមិតព្វវត្ថុសមាយោគេ ចស្ស សម្មុខា សត្ថារំ បស្សតោ វិយ ហិរោត្តប្បំ បច្ចុបដ្ឋាតិ *កាលបើមានការជួបប្រសព្វនឹងវត្ថុដែលគួរប្រព្រឹត្តល្មើស ហិរិ និងឱត្តប្បៈ រមែងប្រាដកដល់បុគ្គលនោះនៅចំពោះមុខ ។*

៩. ឧត្តរិ អប្បដិវិជ្ឈន្តោ បន សុគតិបរាយនោ ហោតិ *កាលមិនទាន់ចាក់ធ្លុះនូវគុណធម៌ខ្ពង់ខ្ពស់ រមែងជាអ្នកមានសុគតិទៅខាងមុខ ។*

តស្មា ហវេ អប្បមាទំ    កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ    ពុទ្ធានុស្សតិយា សទា ។

*ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្តីមិនប្រមាទក្នុងពុទ្ធានុស្សតិ ដែលមានអានុភាពច្រើនយ៉ាងនេះ គ្រប់ៗ កាល ។*

## ព្រះបរិត្ត

*បទសូត្រ ៧ ឬ ១២ យ៉ាង ដែលមានឈ្មោះថា បរិត្ត ប្រែថា គ្រឿងឃុំគ្រង ជាទីនិយមស្វាធ្យាយរបស់ពុទ្ធសាសនិក តាំងតែសម័យពុទ្ធកាល រហូតដល់បច្ចុប្បន្ន ដើម្បីបានសិរីមង្គល និងជាការចម្រើនភាវនាបារមី ។*

*ព្រះបរិត្តដែលប្រាកដក្នុងព្រះសូត្រមានដូចនេះ*

**១. មង្គលបរិត្ត** *មានក្នុងខុទ្ទកនិកាយ ខុទ្ទកបាឋ បិដកលេខ ៥២ ទំព័រ ៤ និងខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ៨៦ ។*

**២. រតនបរិត្ត** *មានក្នុងខុទ្ទកនិកាយ ខុទ្ទកបាឋ បិដកលេខ ៥២ ទំព័រ ៦ និងខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ៧៣ ។*

**៣. មេត្តបរិត្ត** *មានក្នុងខុទ្ទកនិកាយ ខុទ្ទកបាឋ បិដកលេខ ៥២ ទំព័រ ១៨ និងខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ៥០ ។*

**៤. ខន្ធបរិត្ត** *មានក្នុងវិនយបិដក ចូឡវគ្គ បិដកលេខ ១០ ទំព័រ ១៤០ និងអង្គុត្តរនិកាយ ចតុក្កនិបាត អហិរាជសូត្រ បិដកលេខ ៤២ ទំព័រ ១៧៩ និងខុទ្ទកនិកាយ ជាតក ទុកនិបាត ខណ្ឌជាតក បិដកលេខ ៥៨ ទំព័រ ១០២ ។*

**៥. មោរបរិត្ត** *មានក្នុងខុទ្ទកនិកាយ ជាតក ទុកនិបាត បិដកលេខ ៥៨ ទំព័រ ១៥៩ ។*

**៦. វដ្ដកបរិត្ត** *មានក្នុងខុទ្ទកនិកាយ ជាតក ទុកនិបាត បិដកលេខ ៥៨ ទំព័រ ១១៨ និង ខុទ្ទកនិកាយ ចរិយាបិដក បិដកលេខ ៧៧ ទំព័រ២៩៨*

**៧. ធជគ្គបរិត្ត** មានក្នុងសំយុត្តនិកាយ សគាថវគ្គ បដិកលេខ ៣០ ទំព័រ ២៤៣ ។

**៨. អាដានាដិយបរិត្ត** មានក្នុងទីឃនិកាយ បាដិកវគ្គ បិដកលេខ ១៩ ទំព័រ ៩៤ ។

**៩. អង្គុលិមាលបរិត្ត** មានក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក បដិកលេខ ២៤ ទំព័រ ៤១៨ ។

**១០. ពោជ្ឈង្គបរិត្ត** មានក្នុងសំយុត្តនិកាយ មហាវគ្គ បិដកលេខ ៣៧ ទំព័រ ២០៥

**១១. បុព្វណ្ហបរិត្ត** មានក្នុងអង្គុត្តរនិកាយ តិកនិបាត បុព្វណ្ហសូត្រ បិដកលេខ ៤១ ទំព័រ ៤៧៦ ។

**១២. ឥសិគិលិបរិត្ត** មានក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក បដិកលេខ ២៦ ទំព័រ ៣២៨ ។

## ពាក្យថា ព្រះបរិត្ត

ព្រះបរិត្ត ប្រែថា គ្រឿងឃុំគ្រង គឺការពារអន្តរាយខាងក្រៅ មានចោរ យក្ស សត្វតិរច្ឆាន និងការពារអន្តរាយខាងក្នុងមានរោគ ភ័យ ជំងឺតម្កាត់ជាដើម អានិសង្សដែលបានទទួលពីការសូត្រព្រះបរិត្តនេះ កើតពីអានុភាពរបស់ព្រះរតនត្រ័យ និងអានិសង្សពីការផ្សាយមេត្តា ព្រោះព្រះបរិត្តទាំងនេះពោលដល់គុណ របស់ព្រះរតនត្រ័យ និងការចម្រើនមេត្តាភាវនា ដូច្នោះ អ្នកស្វាធ្យាយព្រះបរិត្តទើបបានទទួលផលានិសង្សផ្សេងៗ ដូចជា ប្រសព្វសិរីសួរស្តី សេចក្តីចម្រើនរុងរឿង បានទទួលជ័យជម្នះ រួចផុតពី

ឧបសគ្គ អន្តរាយ មានសុខភាពល្អ និងមានអាយុយឺនយូរ សមដូចព្រះពុទ្ធតម្រាស់ថា អ្នកចម្រើនពុទ្ធានុស្សតិ ដែលជាភាវនាដ៏ល្អប្រសើរក្នុងភាវនាធម៌ ព្រោះអ្នកចម្រើនភាវនានេះ នឹងសម្រេចតាមសេចក្តីប្រាថ្នា ។

## អានុភាពព្រះបរិត្ត

ព្រះបរិត្ត គឺគ្រឿងឃុំគ្រងរក្សា មិនឲ្យមានឧបទ្រពអន្តរាយ ឬបញ្ចៀសឧបទ្រពអន្តរាយ ដែលកើតឡើងហើយ ។

## អង្គរបស់អ្នកសូធ្យមាន ៣

១. អត្ថញ្ច ព្យញ្ជនញ្ច បរិសោធេត្វា សុដ្ឋុ ឧគ្គហិតា ជម្រះអត្ថ និងព្យញ្ជនៈ ហើយរៀនយកដោយល្អ ។

២. បទព្យញ្ជនានិ អហាបេត្វា បរិបុណ្ណំ ឧគ្គហិតា មិនឲ្យបទ និងព្យញ្ជនៈទាំងឡាយបាត់បង់ ហើយរៀនយកដោយបរិបូណ៌ ។

៣. និស្សរណបក្ខេ ឋត្វា មេត្តំ បុរេចារិកំ កត្វា ករណាន្តស្សេវ អត្ថាយ ហោតិ តាំងនៅក្នុងចំណែកនៃការចេញចាកទុក្ខ ហើយធ្វើមេត្តាឲ្យប្រព្រឹត្តទៅក្នុងខាងមុខ ពោលឲ្យកើតជាប្រយោជន៍ ។ (សុមង្គលវិលាសិនី អដ្ឋកថាសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ)

## សូម្បីអ្នកស្តាប់ព្រះបរិត្ត ក៏ត្រូវមានអង្គ ៣ គឺ

១. មិនធ្លាប់ធ្វើអនន្តរិយកម្ម ៥ ណាមួយ ។

២. មិនមានមិច្ឆាទិដ្ឋិ យល់ឃើញខុសថា កម្មនិងផលកម្មមិនមាន ។

៣. ជឿជាក់អានុភាពព្រះបរិត្តថាមានពិត អាចគ្រប់គ្រងរក្សាអ្នកស្តាប់បាន ។ (មិលិន្ទបញ្ហា)

**ព្រះបរិត្តមិនឃុំគ្រងរក្សាបុគ្គល ៣ ពួក**

កម្មំ ចេវ កិលេសោ ច អសទ្ធហាន ជាតិមេ

សចេ អត្ថិ សុណន្តម្ហិ បរិត្តំ តំ ន រក្ខតិ ។

*ព្រះបរិត្តនោះ រមែងមិនឃុំគ្រងបុគ្គល ៣ ពួក គឺ អ្នកធ្វើអនន្តរិយកម្ម ៥ (គឺ សម្លាប់បិតា សម្លាប់មាតា សម្លាប់ព្រះអរហន្ត ធ្វើសង្ឃភេទ និងធ្វើលោហិតុប្បាទ) ១ អ្នកមានសេចក្តីយល់ឃើញខុស ១ អ្នកមិនជឿអានុភាពរបស់ព្រះបរិត្ត ១ ។*

**អង្គរបស់អ្នកស្វាធ្យាយព្រះបរិត្តមាន ៣ ប្រការ ចងជាគាថា**

ចាឡិក្ខរំ អនាសេត្វា អត្ថំ ជានិយ សាធុកំ

អនុទ្ធយំ ករិត្វាន ភណេ បរិត្តមុត្តមំ ។

*អ្នកស្វាធ្យាយព្រះបរិត្តដ៏ប្រសើរ គប្បីមានអង្គ ៣ ប្រការ គឺ ស្វាធ្យាយត្រូវ មិនខុសអក្ខរៈ ១ យល់នូវអត្ថ ១ មានមេត្តាដល់អ្នកស្តាប់ ១ ។*

*អ្នកស្វាធ្យាយ និងអ្នកស្តាប់គប្បីប្រកបដោយអង្គដែលជាគុណទាំងនេះ ព្រះបរិត្តទើបឃុំគ្រងរក្សាមិនឲ្យកើតឧបទ្រពអន្តរាយបាន ។*

**មហានមស្ការ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*សូមនមស្ការដល់ព្រះមានព្រះភាគទ្រង់ឆ្ងាយចាកកិលេស*

*ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯងអង្គនោះ ។*

*បោរាណាចារ្យហៅបទនេះថា* **មហានមស្ការ** *គឺជាបទនមស្ការថ្វាយបង្គំដ៏សំខាន់ក្រៃលែង* **(សទ្ទនីតិ បទមាលា បានសម្ដែងថា** ឯត្ថ មហា-នមក្ការោ នាម "នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស" តិ ចាហុ ។**)** *អាស្រ័យមកពីជាបទដំបូងដែលពុទ្ធបរិស័ទនិយមសូធ្យនមស្ការព្រះសម្មាសម្ពុទ្ធ ។ ក្នុងសម័យពុទ្ធកាលមានបុគ្គលច្រើនរូប ដែលបន្លឺឧទានពាក្យនេះ ដើម្បីនមស្ការព្រះពុទ្ធជាម្ចាស់ ដូចសក្កទេវរាជ ព្រហ្មាយុព្រាហ្មណ៍ អារាមទណ្ឌព្រាហ្មណ៍ នាងធនញ្ជានី និងព្រះបាទបសេនទិកោសលជាដើម ដូចមានប្រាកដក្នុងសូត្រនោះៗ ។*

*អាចារ្យពួកខ្លះមានមតិថា ទេព ៥ ពួក ពោលបទនេះជាខាងដើម គឺសាតាគិរិយក្ខ ពោលថា* **នមោ** *អសុរិន្ទរាហូពោលថា* **តស្ស** *ស្ដេចចាតុ-មហារាជិកាពោលថា* **ភគវតោ** *សក្កទេវរាជពោលថា* **អរហតោ** *មហាព្រហ្មពោលថា* **សម្មាសម្ពុទ្ធស្ស** *ដូចមានគម្ពីរកច្ចាយនភេទទីកាពោលថា*

សាតាគិរិ នមោ យក្ខោ តស្ស ច អសុរិន្ទកោ
ភគវតោ មហារាជា សក្កោ ច អរហតោ តថា
សម្មាសម្ពុទ្ធស្ស ព្រហ្មា ច ឯតេ បញ្ច បតិដ្ឋិតា ។

*យ៉ាងណាក៏ដោយ បណ្ឌិតទាំងឡាយមិនព្រមទទួលយកមតិនេះព្រោះមិនមាន សំដែងឲ្យប្រាកដក្នុងព្រះបាលី* **(បិដក)** *និងអដ្ឋកថាទាំងឡាយ ទាំងក្នុងព្រះបាលីក៏ប្រាកដថា ជាពាក្យឧទានដែលបុគ្គលតែ*

*ម្នាក់ៗ ពោលឡើង ។ តទៅនេះ ខ្ញុំនឹងលើកបទបាលីក្នុងព្រះត្រៃបិដកមកបញ្ជាក់ ដើម្បីឲ្យឃើញថា* នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស *នេះ ជាពាក្យឧទានឡើងរបស់បុគ្គលតែម្នាក់ៗ មិនមែនជាពាក្យផ្សំឡើងរបស់បុគ្គល ៥ នាក់នោះទេ ។*

### ១. ជាពាក្យឧទានឡើងរបស់សក្កទេវរាជ

អថ ខោ សក្កោ ទេវានមិន្ទោ ចាណិនា បថវឹ បរាមសិត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

*គ្រានោះ សក្កទេវរាជជាធំជាងពួកទេវតា ទ្រង់យកព្រះហស្តទះផែនដី ហើយបន្លឺនូវឧទានអស់វារៈ ៣ ដងថា សូមនមស្ការថ្វាយបង្គំចំពោះព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

*(សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ សក្កបញ្ហសូត្រ បិដកលេខ ១៧ ពំទ័រ ២៤២)*

### ២. ជាពាក្យឧទានឡើងរបស់ជាណុស្សោណិព្រាហ្មណ៍

ឯវំ វុត្តេ ជាណុស្សោណិ ព្រាហ្មណោ សព្វសេតា វឡវាភិរថា ឱរោហិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*កាលបិលោតិបរិព្វាជក ពោលយ៉ាងនេះហើយ ជាណុស្សោណិ-ព្រាហ្មណ៍ក៏ចុះអំពីរថ ដែលទឹមដោយសេះសសុទ្ធ ធ្វើសំពត់ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីឆ្ពោះទៅ ត្រង់ទីដែលមានព្រះមានព្រះភាគគង់នៅ បន្លឺឧទានវាចា អស់វារៈ ៣ ដងថា សូមនមស្កាចំពោះ ព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនស្ការចំពោះព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការចំពោះព្រះមានព្រះភាគជាព្រះអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ។*

*(សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ ចូឡហត្ថិបទោបមសូត្រ បិដកលេខ ២១ ទំព័រ ១៧៥-៦)*

### ៣. ជាពាក្យឧទានឡើងរបស់ព្រះបាទបសេនទិកោសល

អថ ខោ រាជា បសេនទិ កោសលោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

*តពីនោះមក ព្រះបាទបសេនទិកោសល ក្រោកអំពីអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈ ឆៀងព្រះអង្សាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះត្រង់ទីព្រះមានព្រះភាគគង់ បន្លឺនូវឧទាន អស់វារៈ ៣ ដងថា ខ្ញុំសូមថ្វាយបង្គំចំពោះព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះភគវន្ត*

*អរហន្តសម្មាសម្ពុទ្ធអង្គនោះ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះភគវន្តអរហន្ត សម្មាសម្ពុទ្ធ អង្គនោះ ។*

*(សុត្តន្តបិដក មជ្ឈិមនិកាយ ជម្ឈិមបណ្ណាសកៈ បិយជាតិកសូត្រ បិដកលេខ ២៤ ទំព័រ ៤៥៥)*

**៤. ជាពាក្យឧទានឡើងរបស់ព្រហ្មាយុព្រាហ្មណ៍**

ឯវំ វុត្តេ ព្រហ្មាយុ ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេតិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

*កាលបើឧត្តរមាណព ពោលយ៉ាងនេះហើយ ព្រហ្មាយុព្រាហ្មណ៍ ក៏ក្រោកអំពីអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គៈជៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះត្រង់ទីដែលព្រះមាន ព្រះភាគគង់ បន្លឺនូវឧទានវាចា អស់វារៈ ៣ ដងថា សូមថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ... សូមថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ សូមថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

*(សុត្តន្តបិដក មជ្ឈិមនិកាយ ជម្ឈិមបណ្ណាសកៈ ព្រហ្មាយុសូត្រ បិដកលេខ ២៥ ទំព័រ ១៩)*

### ៥. ជាពាក្យឧទានឡើងរបស់នាងធនញ្ជានីព្រាហ្មណី

អថ ខោ ធនញ្ជានី ព្រាហ្មណី ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស ភត្តំ ឧបសំហរន្តី ឧបក្ខលិត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

*លំដាប់នោះឯង នាងធនញ្ជានីព្រាហ្មណី កំពុងចាត់ចែងភត្ត ដើម្បីព្រាហ្មណ៍ភារទ្វាជគោត្រ ក៏ភ្លាត់បន្ទឺនូវឧទានបីដងថា សូមថ្វាយបង្គំព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមថ្វាយបង្គំព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ អង្គនោះ សូមថ្វាយបង្គំ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

*(សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ ធនញ្ជានីសូត្រ បិដកលេខ ៣០ ទំព័រ ៨៣-៤)*

### ៦. ជាពាក្យឧទានឡើងរបស់អារាមទណ្ឌព្រាហ្មណ៍

ឯវំ វុត្តេ អារាមទណ្ឌោ ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណំ ជាណុមណ្ឌលំ បឋវិយំ និហន្ត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ

អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*លុះព្រះកច្ចានៈដ៏មានអាយុ សំដែងយ៉ាងនេះហើយ ទើបអារាមទណ្ឌព្រាហ្មណ៍ ក្រោកចាកទីអង្គុយ ធ្វើសំពត់ដណ្តប់ឆៀងស្មាម្ខាង លុតមណ្ឌលជង្គង់ ខាងស្តាំលើផែនដី ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ បន្លឺនូវឧទានអស់វារៈ ៣ ដងថា សូមក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

*(សុត្តន្តបិដក អង្គុត្តរនិកាយ ទុកនិបាត សមចិត្តវគ្គ បិដកលេខ ៤០ ទំព័រ ១៤៩)*

## ៧. ជាពាក្យឧទានឡើងរបស់ការណបាលីព្រាហ្មណ៍

ឯវំ វុត្តេ ការណបាលី ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណំ ជាណុមណ្ឌលំ បឋវិយំ និហន្ត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

*កាលដែលបិង្គិយានិព្រាហ្មណ៍ ពោលយ៉ាងនេះហើយ ការណោបាលិ-ព្រាហ្មណ៍ ក៏ក្រោកចាកអាសនៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយលុតមណ្ឌលជង្គង់ ខាងស្តាំលើផែនដី ប្រណម្យអញ្ជលីចំពោះទៅព្រះដ៏មានព្រះភាគ ហើយបន្លឺនូវឧទានជាគម្រប់ ៣ ដងថា សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

*(សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ព្រាហ្មណវគ្គ ការណោបាលីសូត្រ បិដកលេខ ៤៥ ទំព័រ ២២១)*

### ៨. ជាពាក្យឧទានឡើងរបស់ព្រះបាទមហិន្ទរាជ

រាជា សត្ថុ សន្តិកំ គន្ត្វា ‘ជេដ្ឋបុត្តោ មេ ពុទ្ធោ, កនិដ្ឋបុត្តោ បឋមអគ្គសាវកោ, បុរោហិតបុត្តោ ទុតិយអគ្គសាវកោ’តិ តេ ឱលោកេត្វា, ‘មមេវ ពុទ្ធោ, មមេវ ធម្មោ, មមេវ សង្ឃោ, នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សា’តិ តិក្ខត្តុំ ឧទានំ ឧទានេត្វា ។

*ព្រះរាជាមកហើយកាន់សំណាក់នៃព្រះសាស្តា ទ្រង់សម្លឹងមើលហើយនូវបុគ្គលទាំងនោះ ហើយពោលថា បុត្រច្បងរបស់យើងបានជាព្រះពុទ្ធ បុត្រប្អូនបានជាអគ្គសាវ័កទី ១ បុត្ររបស់បុរោហិតបានជា*

អគ្គសាវ័កទី ២ ហើយទ្រង់ក៏បន្ទឹនូវឧទានអស់វារៈបីបង់ថា សូមនមស្ការ ដល់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

(ធម្មបទដ្ឋកថា យមកវគ្គទី ១ សារិបុត្តត្ថេរវត្ថុទី ៨)

# នមស្ការនិងបរិត្តបាលិ


| មាតិកា | បិដ្ឋង្ក |
|---|---|
| អានិសង្សនៃការចម្រើនពុទ្ធានុស្សតិ | ក |
| ព្រះបរិត្ត | គ |
| អានុភាពព្រះបរិត្ត | ង |
| អង្គរបស់អ្នកសូធ្យ | ង |
| អង្គរបស់អ្នកស្តាប់ | ង |
| ព្រះបរិត្តមិនឃុំគ្រងរក្សាបុគ្គល ៣ ពួក | ច |
| អង្គរបស់អ្នកស្វាធ្យាយព្រះបរិត្តមាន ៣ ប្រការ ចងជាគាថា | ច |
| មហានមស្ការ | ច |
| មាតិកា | ណ |
| បទសរភញ្ញ | ១ |
| បទលើកទង់ព្រះពុទ្ធសាសនា | ២ |
| កំណើតឆព្វណ្ណរង្សី | ៣ |
| នមស្ការ | ៤ |
| ពុទ្ធរតនប្បណាម | ៤ |
| ធម្មរតនប្បណាម | ៨ |
| សង្ឃរតនប្បណាម | ១១ |
| រតនត្តយប្បណាម | ១៥ |
| ចេតិយនមស្ការគាថា | ១៧ |

| | |
|---|---|
| នមស្ការពុទ្ធបាទ | ១៧ |
| សម្ពុទ្ធេ | ១៩ |
| បារមី ៣០ | ២០ |
| ធម្មនិយាម ៣០ | ២០ |
| វិសាខបុណ្ណមី | ២៨ |
| សមាទានសីល ៥ | ២៩ |
| ត្រៃសរណគមន៍ | ២៩ |
| សីល ៥ | ៣០ |
| សមាទានសីល ៨ | ៣១ |
| សីល ៨ | ៣១ |
| បត្តិទានគាថា | ៣៣ |
| យំ កិញ្ចិ ប្រែកាព្យ | ៣៤ |
| យំ កិញ្ចិ ប្រែកាព្យមួយបែបទៀត | ៣៤ |
| វិសាខាឧទាន | ៣៥ |
| តេជះខ្ញុំសាង | ៣៥ |
| តាំងសេចក្តីប្រាថ្នា | ៣៦ |
| បត្តិទាន | ៣៧ |
| ផ្សាយមេត្តាក្នុងទិសទាំង ១០ | ៣៧ |
| ឧទ្ទិសបុណ្យដល់ទេវតានិងនាគ | ៤១ |
| អធិដ្ឋានសាសនា | ៤២ |

# បរិត្តចាលិ

ធម្មស្សវនកាល ៤៣
នមក្ការ ៤៣
សរណាត្តយ ៤៣
ទេវនិមន្តនគាថា ៤៣
ទេវសន្និបាតគាថា ៤៤
បត្ថនាគាថា ៤៤
មេត្តាអាសីសគាថា ៤៤
ធម្មស្សវនានិសំសកថា ៤៤
ភាណាភិយាចនកថា ៤៥
១. មង្គលសុត្ត ៤៥
បរិត្តគុណកថា ៤៧
២. រតនសុត្ត ៤៨
ភាណាភិយាចនកថា ៥៤
៣. មេត្តសុត្ត ៥៤
ភាណាភិយាចនកថា ៥៧
៤. ខន្ធបរិត្ត ៥៧
ភាណាភិយាចនកថា ៥៩
៥. មោរបរិត្ត ៥៩
ភយាភិយាចនកថា ៦១

| | |
|---|---|
| ៦. វដ្ដកបរិត្ត | ៦១ |
| កយាភិយាចនកថា | ៦២ |
| ៧. ធជគ្គសុត្ត | ៦២ |
| កយាភិយាចនកថា | ៦៧ |
| ៨. អាដានាដិយបរិត្ត | ៦៧ |
| ភាណាភិយាចនកថា | ៧១ |
| ៩. អង្គុលិមាលបរិត្ត | ៧២ |
| ភាណាភិយាចនកថា | ៧២ |
| ១០. ពោជ្ឈង្គបរិត្ត | ៧២ |
| ភាណាភិយាចនកថា | ៧៤ |
| ១១. បុព្វណ្ហបរិត្ត | ៧៤ |
| ១២. ឥសិគិលិសុត្ត | ៧៨ |

# បទសរភញ្ញ

| | |
|---|---|
| សូមថ្វាយបង្គំព្រះសម្ពុទ្ធ | ប្រសើរបំផុតក្នុងលោកា |
| ជាគ្រូនៃមនុស្សនិងទេវតា | ទ្រង់ត្រាស់ទេសនាប្រដៅសត្វ |
| ចង្អុលឲ្យដើរផ្លូវកណ្តាល | មាគ៌ាត្រកាលអាចកម្ចាត់ |
| ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់ | អាចកាត់សង្សារទុក្ខបាន ។ |
| សាសនាព្រះអង្គនៅសព្វថ្ងៃ | សត្វមាននិស្ស័យពីបុរាណ |
| ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន | កាន់តាមលម្អានបានក្តីសុខ |
| ឥតមានសុខណាស្មើក្តីស្ងប់ | បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ |
| តាំងពីលោកនេះតទៅមុខ | ក្តីសុខនឹងមានព្រោះធម៌ស្ងប់ ។ |
| ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ | ព្រះសង្ឃបវរទាំងគ្រប់សព្វ |
| រួមជាត្រៃរត័ន៍គួរគោរព | ជាម្លប់ត្រជាក់នៃលោកា |
| ព្រះរូបព្រះធាតុនៃព្រះពុទ្ធ | វិសុទ្ធតាងអង្គព្រះសាស្តា |
| សូមគុណត្រៃរត័ន៍ជួយខេមរា | ឲ្យបានសុខាតរៀងទៅ ។ |

# បទលើកតម្កើងព្រះពុទ្ធសាសនា

សូមមើលទង់ជ័យឆព្វណ្ណរង្សី    ដែលមានរស្មីដ៏ភ្លឺស្រស់ល្អ
ខៀវលឿងក្រហមព្រមទាំងពណ៌ស    ហង្សបាទនិងពណ៌ដ៏សែនភ្លឺថ្លែក ។
ប្រទេសតូចធំបានស្ម័គ្រស្មាគម    ជំនុំគ្នាច្រើនដ៏អនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក    ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញាទង់ជ័យសាសនា    នៃសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នាយកចិត្តចងចាំ    នឹកដល់ព្រះអង្គជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នាក៏ត្រូវដឹងថា    សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គីទាំងក្មេងទាំងចាស់    ប្រឹងប្រែងឲ្យណាស់ឲ្យគ្រប់ៗគ្នា ។
សូមសាសនាពុទ្ធថ្កុំថ្កើងបំផុត    រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជោគជ័យផ្សាយពេញលោកា    ដោយជនជ្រះថ្លាច្រើនសែនលាន។
មានចិត្តស្នេហាគោរពបូជា    ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតាស្នេហាគ្រប់ប្រាណ    ប្រាថ្នាចង់បានសេចក្តីសុខ។
យើងខេមរជាតិនាំគ្នាខ្មីឃ្មាត    កាន់ធម៌នឹងបានរួចចាកទុក្ខ
រួបរួមសាមគ្គីពីនេះទៅមុខ    យើងនឹងបានសុខក្សេមក្សាន្តត្រាណ ។
ព្រមព្រៀងប្រព្រឹត្តកាន់ធម៌សុចរិត    ឆ្ពោះទៅកាន់ឋាននិព្វាន
ជាទីផុតទុក្ខបានសុខក្សេមក្សាន្ត    ជាតិយើងនឹងបានសោយសុខា ។

## កំណើតឆព្វណ្ណរង្សី

ជាតិយើងអ្នកកាន់សាសនា　ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី　គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
ផ្សាយចេញពីព្រះកាយទ្រង់　រុងរឿងឫទ្ធិរុងប្រសើរបវរ
ឆ្មៀលឆ្វាត់កាយឆើតឆាយល្អ　ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
កំណើតនៃព្រះរស្មី　កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា　កាលដែលនៅជាព្រះពោធិសត្វ ។
រស្មីពណ៌ខៀវនោះណា　កាលឆ្មៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត　កាលនៅជាក្សត្រនាមស្រីពិរាស្រ្ត ។
រស្មីពណ៌លឿងភ្លឺថ្លា　កាលដែលទ្រង់អារសាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស　ព្រះឥន្ទជាងមាសទ្រង់វៃបណ្ឌិត។
រស្មីក្រហមនោះណា　កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត　កាត់បេះដូងបិទធ្វើថ្នាំមាតា　។
រស្មីពណ៌សសុទ្ធសាធ　កាលជាព្រះបាទវេស្សន្តរក្សត្រា
ឲ្យទានដំរីសសោភា　ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ។
រស្មីពណ៌ដូចជើងហង្ស　កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ　ឲ្យយក្សសាមានស៊ីប្តូរជីវិត ។
រស្មីភ្លឺផ្ទេកពណ្ណរាយ　កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឲ្យទានសាច់ឈាមជីវិត　ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
រស្មីខៀវលឿងក្រហម　សហង្សបាទព្រមភ្លឺផ្ទេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ　ក្មេងចាស់កុមារចូរចាំទុកអើយ ។

## នមស្ការ

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*វីកិរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

*( ក្រាបថ្វាយបង្គំម្តង )*

## ពុទ្ធរតនប្បណាម

**យោ សន្និសិន្នោ វរពោធិមូលេ**

**មារំ សសេនំ មហតឹ វិជេយ្យោ**

**សម្ពោធិមាគច្ឆិ អនន្តញាណោ**

**លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។**

*ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើន នូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។*

*( ក្រាបថ្វាយបង្គំម្តង )*

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។**

*ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបាន ត្រាស់ជាព្រះពុទ្ធ ក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងកទ្ទកប្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយ បង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។*

*( ក្រាបថ្វាយបង្គំម្តង )*

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។**

**ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនាគឺកាយបយោគ និងវចីបយោគ* **សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ* **វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥* **សុគតោ** *ទ្រង់ព្រះនាម*

ថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថានគឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា *លោកវិទូ* ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា *អនុត្តរោ* ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន **បុរិស~ទម្មសារថិ** ទ្រង់ព្រះនាមថា *បុរិសទម្មសារថិ* ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា *សត្ថា ទេវមនុស្សានំ* ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា *ពុទ្ធោ* ព្រោះព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា *ភគវា* ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

( ក្រាបថ្វាយបង្គំម្តង )

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ**

**ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង* **ពុទ្ធេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់* **ពុទ្ធោ ខមតុ តំ មមំ** *សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។*

*( ក្រាបថ្វាយបង្គំម្តង )*

**ធម្មរតនប្បណាម**

**អដ្ឋង្គិកអរិយបថោ ជនានំ**

**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**

**ធម្មោ អយំ សន្តិករោ បណីតោ**

**និយ្យានិកោ តំ បនមាមិ ធម្មំ ។**

*ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញុំាងជន ដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឲ្យត្រជាក់រំងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តមជាគុណ ញុំាងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព ។*

*( ក្រាបថ្វាយបង្គំម្តង )*

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**

**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

*ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី*

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ( **ធម្មោ** ព្រះនព្វ-លោកុត្តរធម៌ មាន ៩ ប្រការ គឺ មគ្គ ៤ ផល ៤ និព្វាន ១ ) **សន្ទិដ្ឋិកោ** ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិត ដោយបច្ចវេក្ខណ-ញ្ញាណគឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានឃឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្ស-វិធី គឺថាបើព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺ ព្រះអរិយ-បុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

( ក្រាបថ្វាយបង្គំម្តង )

**នត្ថិ មេ សរណំ អញ្ញំ    ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន    ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណា មិនមានឡើយ* **ធម្មោ មេ សរណំ វរំ** *មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

**ឧត្តមង្គេន វន្ទេហំ    ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ    ធម្មោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** *ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមាន ២ ប្រការ គឺ ព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង* **ធម្មេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់* **ធម្មោ ខមតុ តំ មមំ** *សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។*

*( ក្រាបថ្វាយបង្គំម្តង )*

## សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**គុណេហិ នេកេហិ សមិទ្ធិបត្តោ**

**អនាសវោ តំ បណមាមិ សង្ឃំ ។**

*ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរំងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយា សម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។*

*( ក្រាបថ្វាយបង្គំម្តង )*

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**

**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

*ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល កន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី*

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

**សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិ-ប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

**សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌* **ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា* **ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេមផុតចាកទុក្ខទាំងពួង* **សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា*

**យានិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរស ទាំងឡាយ មាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផល ជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផល ជាគូ ១ អនាគាមិមគ្គ និងអនាគាមិផល ជាគូ ១ អរហត្តមគ្គ និងអរហត្តផល ជាគូ ១ **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គល មាន ៨ គឺព្រះសង្ឃ ដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជា សង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវ ចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពី ចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្ត ដែលមកអំពីទិសផ្សេង ៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែល បុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា **អញ្ជលិករណីយោ** លោកគួរ ដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃ ក្រៃលែងជាងគ្មាន ។

( ក្រាបថ្វាយបង្គំម្តង )

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំ ព្រះករុណា មិនមានឡើយ* **សង្ឃោ មេ សរណំ វរំ** *មានតែព្រះសង្ឃជាម្ចាស់ជាទីពឹង ទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មាន ២ ប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តម គឺត្បូង* **សង្ឃេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់* **សង្ឃោ ខមតុ តំ មមំ** *សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

*( ក្រាបថ្វាយបង្គំម្តង )*

## រតនត្តយប្បណាម

**យោ កប្បកោដីហិបិ អប្បមេយ្យំ**

**កាលំ ករោន្តោ អតិទុក្ករានិ**

**ខេទំ គតោ លោកហិតាយ នាថោ**

**នមោ មហាការុណិកស្ស តស្ស ។**

*ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា ព្រះអង្គកាលប្រាថ្នា ធ្វើកសាង អស់កាលយូរ រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ បាន ត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើកពឋាន ធ្វើកម្មជាកម្រ សត្តនិករគ្រាប់ ពុំបាន តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ខ្ញុំសូមឱន សិរសា ចិត្តប្រាថ្នាបង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វនោះជាទីពឹងសព្វកាល ។*

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ**

**ភវាភវំ គច្ឆតិ ជីវលោកោ**

**នមោ អវិជ្ជាទិកិលេសជាល~**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

*សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល ឲ្យវិលវល់ អន្ទោល ក្នុងភពតូចនិងភពធំ ហេតុតែមិនដឹងធម៌ជាម្ចាស់ល្អស្អាតសុខុម គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះ ឯងណា កាត់បង់នូវអវិជ្ជាគឺបណ្តាញកិលេសហើយ ។*

**គុណេហិ យោ សីលសមាធិបញ្ញា-**

**វិមុត្តិញាណប្បភុតីហិ យុត្តោ**

**ខេត្តំ ជនានំ កុសលត្ថិកានំ**

**តមរិយសង្ឃំ សិរសា នមាមិ ៕**

*ព្រះសង្ឃអគ្គសាវក មានសំវរៈសទ្ធាទ្រទ្រង់ កបដោយគុណសីលត្រង់ និងសមាធិបញ្ញា និងវិមុត្តិញាណ កិលេសគ្មានក្នុងអាត្មា ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។*

**ឥច្ចេវមច្ចន្តនមស្សនេយ្យំ**

**នមស្សមានោ រតនត្តយំ យំ**

**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ**

**តស្សានុភាវេន ហតន្តរាយោ ៕**

*ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារា ដូចជលសាធំទូលាយ សូមឲ្យកម្ចាត់បង់ អពមង្គលទាំងឡាយ ឲ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ដោយគុណនមស្ការត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។*

## ចេតិយនមស្ការគាថា

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**

**សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ។**

*ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះបរមចេតិយ៍ ព្រមទាំងព្រះសារីរិកធាតុនៃព្រះពុទ្ធ និងមហាពោធិព្រឹក្ស ដែលគួរទឹកដោយលំអុត លំឱនចិត្តបរិសុទ្ធលើកកម្បង់អញ្ជលី និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី ដែលឋិតនៅគ្រប់ទីឋាននានានោះទាំងអស់ ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ សូមឲ្យខ្ញុំបានសុខ រួចចាកទុក្ខផងទាំងឡាយ សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត សូមទាន់ព្រះអរិយមេត្រេយ្យថ្លៃវិសិដ្ឋ សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។*

## នមស្ការពុទ្ធបាទ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។**

*ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអនន្ត ឲ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុត អំពីប្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។*

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ តំ បាទលញ្ឆ នមហំ សិរសា នមាមិ ។**

*ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) លើផ្នូរខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា ( ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំ ដោយត្បូង ចំពោះទៅព្រះបាទ និង ស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី ។*

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

*ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺស្ថានលើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។*

## **សម្ពុទ្ធេ**

**សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ**

**បញ្ចសតសហស្សានិ នមាមិ សិរសា អហំ ។**

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ ព្រះអង្គផង ១ ម៉ឺន ២ ពាន់ ព្រះអង្គផង ៥ សែន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។*

**សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ**

**ទសសតសហស្សានិ នមាមិ សិរសា អហំ ។**

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ ពាន់ ព្រះអង្គផង ១ លាន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។*

**សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ**

**វីសតិសតសហស្សានិ នមាមិ សិរសា អហំ ។**

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ១០៩ ព្រះអង្គផង ៤ ម៉ឺន ៨ ពាន់ ព្រះអង្គផង ២ លាន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា) ។*

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ ។**

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។*

**នមក្ការានុភាវេន    ហន្ត្វា សព្វេ ឧបទ្ទវេ**
**អនេកា អន្តរាយាបិ    វិនស្សន្តុ អសេសតោ ។**

*ដោយអានុភាព នៃកិរិយានមស្ការថ្វាយបង្គំ សូមឲ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយ ជាអនេកក៏ចូរឲ្យវិនាសទៅកុំបីមានសេសសល់ឡើយ ។*

## បារមី ៣០

**ឥតិបិ ទានបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ ទានឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ ទានបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ សីលបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ សីលឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ សីលបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ នេក្ខម្មបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ នេក្ខម្មឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ នេក្ខម្មបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ បញ្ញាបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ បញ្ញាឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ បញ្ញាបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ វីរិយបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវីរិយបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ វីរិយឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវីរិយឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ វីរិយបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវីរិយបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ ខន្តិបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តិបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ ខន្តិឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តិឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ ខន្តិបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តិបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ សច្ចបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ មេត្តាឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ មេត្តាបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ ឧបេក្ខាបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ ឧបេក្ខាឧបបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាឧបបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ ឧបេក្ខាបរមត្ថបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបរមត្ថបារមី សូម្បីព្រោះហេតុដូច្នេះ ។

**ឥតិបិ សមត្តឹសបារមិសម្បន្នោ សោ ភគវា** ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមីទាំង៣០ សូម្បីព្រោះហេតុដូច្នេះ ។

## ធម្មនិយាម ៣០

សូមក្រាបបង្គំប្រណម្យវន្ទា ខ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា ។
មួយរញ្ជួយភពជាតិគ្រប់ចុងក្រោយ បារមីនាំឲ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្នារតីល្អជា ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
ពីរគឺព្រះភក្រ្តវរលក្ខណ៍ក្នុងគភ៌ ស្ថិតស្នាធីក្នុងធម៌បវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា ខ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
បីឥរិយាបថនៃព្រះមាតា ពេលគ្រប់មាសាសាស្តាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ ប្រសូតបុត្រថ្ងៃហឫទ័យជ្រះថ្លា ។
បួនសួនឧទ្យានទីឋានប្រសូត ក្នុងព្រៃរហូតឈើស្រួតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ ចក្រវាលបព្វតាខ្ទរខ្ទារអ៊ូអរ ។
ប្រាំព្រះប្រសូតចុះស្រួតយាងឈាន ប្រាំពីរជំហានខ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ ទើបបានបន្លឺបន្លឺសីហនាទ ។
ប្រាំមួយប្រមើលទតមើលនិមិត្ត ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត ចិត្តឥតរវាតយាត្រាសាងផ្នួស ។
ប្រាំពីរធីរោផ្តាច់ប្តូរព្យាយាម ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង ។
ប្រាំបីមហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា ។
ប្រាំបួនជួនភ័ព្វទ្រង់ទ្រាប់ស្បូវភ្លាំង ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា បល្ល័ង្កភគវាផុសគ្រាសាយ័ណ្ហ ។
ដប់គាប់ហឫទ័យអានាបានៈ បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់ ដំណើរជវនៃជាន់ឆ្នងកាមា ។
ដប់មួយជំនួយពីព្រះបារមី ផ្ចាញ់មារអប្រិយ៍ព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លាបាចផ្កាអភិសេក ។

ដប់ពីរមុនីអង្គទ្រង់សម្រេចញាណ
ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែកៗ
ពោធិញ្ញាណខ្ពស់ឯកកក្រើកធរណី ។

ដប់បីក្សត្រថ្ងៃគង់ក្នុងមហាឋាន
វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្តាហ៍ឋានមួយលើកសួយស្ថានទី
ចេតិយ៍ព្រះមុនីប្រាំពីរកន្លែង ។

ដប់បួនជូនព្រហ្មជុំអារាធនា
សូមព្រះភគវាយាងត្រាស់សម្តែង
ព្រះធម៌ប្រពៃវិស័យសូរ្យសែង
ទ្រង់ព្រមសម្តែងដោយព្រហ្មវិហារ ។

ដប់ប្រាំចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក
ឥសិបតនៈព្រៃមិគទាយា
ឋានត្រៃរតនៈអាសាឡ្ហបូជា
ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ ។

ដប់ប្រាំមួយទ្រង់គង់ត្រាស់ឱវាទ
បាតិមោក្ខស្អាតស្អាតឱវាទផូរផង់
បេះដូងព្រះធម៌ពន្លឺចតុរង្គ
ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី ។

ដប់ប្រាំពីរទ្រង់គង់វត្តជេតពន
ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី
ទ្រង់យកអរុណាជេតពនសួស្តី
ជេតពនជិនស្រីអាស្រ័យជានិច្ច ។

ដប់ប្រាំបីទ្រង់សម្តែងបាដិហារ្យ
យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច
នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា ។

ដប់ប្រាំបួនទ្រង់គង់ឋានត្រៃត្រិង្ស
ត្រិះរិះរំពឹងថ្លឹងគុណមាតា
សម្តែងអភិធម្មស័ក្តិសមអស្ចារ្យ
ថ្វាយព្រះមាតាសុខាអមតៈ ។

ម្ភៃគឺព្រះអង្គទ្រង់ចាកទេវលោក
ស្តេចយាងចុះមកដែនសង្កស្សៈ
មហាជនច្រើនពិតយកចិត្តទុកដាក់
បូជាគារវៈអចលចេតិយ ។

ម្ភៃមួយគឺទ្រង់គង់ក្នុងសមាបត្តិ
ព្រះញាណស្ងប់ស្ងាត់លះកាត់លោកីយ៍
អរហត្តផលតម្កល់ប្រក្រតី
ធាប់ក្តីយូរក្តីវិស័យពុទ្ធញាណ ។

ម្ភៃពីរប្រមើលមើលគ្រប់វេនេយ្យ
ឧបនិស្ស័យសព្វសត្វដែលមាន
ដោយព្រះករុណាសមាបត្តិញ្ញាណ
ត្រួតសត្វកោដិលានមានពីរវារៈ ។

ម្ភៃបីទ្រង់លៃវិន័យអាជ្ញា
បញ្ញត្តសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវក
មានហេតុជាក់លាក់ទើបដាក់វិន័យ។

ម្ភៃបួនអដ្ឋេនហប្ញទ័យករុណា
ជាតកទេសនាសាស្តាលកលៃ

ដើមរឿងជាហេតុបង្កើតអត្ថន័យ　ជាតកប្រពៃលៃតាមហេតុការណ៍ៗ
ម្តៃប្រាំទ្រង់ប្រោសដល់ពួកព្រះញាតិ　អង្គព្រះលោកនាថសម្តែងបាដិហារ្យ
កម្ចាត់មានះព្រះញាតិវង្សា　ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស ។
ម្តៃប្រាំមួយទ្រង់គង់ធ្វន់ក្នុងធម៌　បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្តេចយាងទទួលស្រុះស្រួលដោយអង្គ　គារវៈផូរផង់ឆ្ពោះត្រង់ព្រះធម៌ៗ
ម្តៃប្រាំពីរទ្រង់គង់ចាំព្រះវស្សា　បើមាននរណានិមន្តដោយល្អ
ពេលចេញវស្សាមុនយាងចេញចរ　ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះៗ
ម្តៃប្រាំបីទ្រង់គង់យ៉ាងហ្មត់ចត់　មុនភត្តក្រោយភត្តគ្មានភ្ញាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចគ្រប់យាមទាំងអស់　ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតាៗ
ម្តៃប្រាំបួនទ្រង់គង់សោយមំសៈ　ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយជាទានថ្ងៃថ្លា　សោយរសមំសាហប្វទ័យបរិសុទ្ធ ។
សាមសិបអវសានទ្រង់បានចូលឈាន　មុននឹងនិព្វានឈានច្រើនបំផុត
ម្តៃបួនសែនកោដិសមាបត្តិបរិសុទ្ធ　រួចហើយទ្រង់ផុតរលត់សង្ខារៗ
អហ៊ឺរខ្ញុំបង្គំវន្ទា　ឆ្ពោះព្រះភគវាព្រះធម៌ថ្ងៃថ្លា
ព្រមទាំងព្រះសង្ឃផូរផង់សីលា　ចិន្តាលំអុតព្រះពុទ្ធនិយាម ។
សូមឲ្យសព្វសត្វបដិបត្តិតាមធម៌　សាសនាបវរល្អដូចព្រះនាម
អរហំសម្មាគ្មានការទាក់ទាម　កិលេសរវាមរវាតសូន្យបង់ ។
សូមឲ្យសាសនាសម្មាសម្ពុទ្ធ　បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចិរកាលអភិបាលដោយសង្ឃ　ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខាៗ
សូមមនុស្សទេវតាមានការគោរព　ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសម្រេចដូចក្តីប្រាថ្នា　អស់នូវតណ្ហាទុក្ខាចប់ហោង ។

# វិសាខបុណ្ណមី

វិសាខបុណ្ណមីគឺថ្ងៃវិសេស　　យើងបានចាំចេះថ្ងៃព្រះភគវា
ប្រាំពីរប្រការជ្រះថ្លាវន្ទា　　វិសាខបូជាឫក្សពារសែនល្អ ។
ទីមួយគឺថ្ងៃសុមេធបណ្ឌិត　　ពោធិសត្វពិតមានឫទ្ធិបវរ
ចាប់ផ្ដើមទទួលព្រះពុទ្ធព្យាករណ៍　　លោកជាតុញាប់ញ័រសោទរពេកក្រៃ។
ទីពីរគឺថ្ងៃក្សត្រថ្ងៃប្រសូត　　អស្ចារ្យរហូតសម្ដោជព្រឹក្សព្រៃ
កំណើតចុងក្រោយជាប់ដោយអត្ថន័យ　　ផុតចាកភពត្រៃលែងភ័យលែងព្រួយ។
ទីបីគឺថ្ងៃព្រះស្រីមហាពោធិ៍　　ដុះចេញលេចឆ្ងោពោធិ៍ពិតមានត្រួយ
ថ្ងៃព្រះប្រសូតស្រូតដុះជាមួយ　　ជំនួយឲ្យចិត្តបរិស័ទជ្រះថ្លា ។
ទីបួនគឺថ្ងៃចមត្រៃត្រាស់ដឹង　　ថ្ងៃមានទីពឹងពំនឹងលោកា
ជាថ្ងៃព្រះពុទ្ធបរិសុទ្ធអស្ចារ្យ　　ពួកជនជ្រះថ្លាចិន្ដាល្អស្អាត ។
ទីប្រាំគឺថ្ងៃអង្គថ្ងៃនិព្វាន　　ថ្ងៃព្រះទ្រង់ញាណមានពុទ្ធោវាទ
បច្ឆិមវាចាថាកុំប្រមាទ　　ឱវាទពិសិដ្ឋឋិតនៅជាគ្រូ ។
ទីប្រាំមួយគឺថ្ងៃប្រល័យព្រះធាតុ　　ចេតិយលោកនាថនៅទៀតមិនយូរ
ព្រះធាតុទាំងអស់ហោះមកគល់ពោធិ៍　　តេជោរំលាយរលត់ពុទ្ធសាសន៍ ។
ប្រាំពីរគឺថ្ងៃជោគជ័យពុទ្ធា　　គ្រប់ព្រះភគវាឈ្នះមារបានត្រាស់
នាំមកនូវសុខវិសេសខ្លាំងណាស់　　គ្រប់អង្គទ្រង់ត្រាស់ព្រះធម៌ទេសនា។
វិសាខបុណ្ណមីថ្ងៃប្រពៃពិត　　យើងខ្ញុំមានចិត្តនឹងជឹងជ្រះថ្លា
វន្ទាសំពះអង្គព្រះសាស្ដា　　សូធ្យធម៌ថ្វាយផ្កាបូជាប្រទីប ។

## សមាទានសីល ៥

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាម ។ ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាម ។ តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចាម ។

## ត្រៃសរណគមន៍

**ពុទ្ធំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។*

**ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។*

**សង្ឃំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។*

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរឭក ជាគម្រប់ ២ ដងផង ។*

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹង ទីរឭក ជាគម្រប់ ២ ដងផង ។*

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរឭក ជាគម្រប់ ២ ដងផង ។*

